**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខៈ ១០៧០ មស. ភ.ឯ.៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងការបើកផ្តល់ប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិលសម្រាប់ខែឧសភា ឆ្នាំ២០១៥

យោងសេចក្តីជូនដំណឹងលេខ១៩ សជណ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥ ស្តីពីករណីការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល នគរបាលជាតិកម្ពុជា យោធិននៃកងយោធពលខេមរភូមិន្ទ សម្រាប់ខែឧសភា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល។

ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមគោរពជម្រាបជូនដំណឹង សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត មេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមអនុវត្តឱ្យបានសម្រេចនូវខ្លឹមសារនៃសេចក្តីជូនដំណឹងដូចមានយោងខាងលើ ក្រសួងមុខងារសាធារណៈ សូមដាក់ចេញនូវសេចក្តីជូនដំណឹងសម្រាប់អនុវត្តនិងសហការអនុវត្តដូចខាងក្រោមៈ

- ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សនិងអាណត្តិបើកប្រាក់បៀវត្សសម្រាប់ខែឧសភា ឆ្នាំ២០១៥ ជូនមន្ត្រីរាជការស៊ីវិលឱ្យបានរួចរាល់ក្នុងសប្តាហ៍ទី១នៃខែឧសភា ឆ្នាំ២០១៥
- ក្រសួងមុខងារសាធារណៈ សូមស្នើសុំក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត មេត្តាផ្តល់ឯកសារពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល មកក្រសួងមុខងារសាធារណៈឱ្យបានត្រឹមថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ ក្នុងករណីដែលក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ផ្តល់ឯកសារខាងលើនេះមិនទាន់ពេលវេលា ក្រសួងមុខងារសាធារណៈ នឹងបោះពុម្ពតារាងទូទាត់បៀវត្សនិងអាណត្តិបើកប្រាក់បៀវត្សជាស្វ័យប្រវត្តិ
- ក្រសួង ស្ថាប័ន ត្រូវជានាការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែឧសភា ឆ្នាំ២០១៥ ជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួន ឱ្យបានយ៉ាងយូរក្នុងសប្តាហ៍ទី៣នៃខែឧសភា ឆ្នាំ២០១៥។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះតាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីស្តីទី**

**យូ ស៊ុនឡុង**

ចម្លងជូនៈ
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ